# សេចក្តីថ្លែងការណ៍រួម

## "ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានជាគន្លឹះសំខាន់ក្នុងការលើកកម្ពស់ការការពារបរិស្ថាន និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា"

អង្គការសង្គមស៊ីវិលកម្ពុជាសូមស្នើអោយរាជរដ្ឋាភិបាល និងស្ថាប័នសភាជាតិអនុម័តច្បាប់សិទ្ធិទទួលព័ត៌មានឱ្យបានឆាប់ស្របតាមបទដ្ឋានអន្តរជាតិ និងធានាបាននូវសិទ្ធិសេរីភាពក្នុងការទទួល ព័ត៌មានក្នុងយុគសម័យឌីជីថលដើម្បីលើកកម្ពស់សេវាសាធារណៈ និងដំណោះស្រាយបញ្ហាប្រឈមនានាលើគ្រប់ វិស័យ ជាពិសេសិទ្ធិទទួលព័ត៌មានបរិស្ថាន និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

បន្ទាប់ពីអស់រយៈពេលជាងមួយទសវត្សរ៍ ដែលសេចក្តីព្រាងច្បាប់ដ៏សំខាន់នេះបានចាប់ផ្តើមតាក់តែងឡើង ប្រជាជនកម្ពុជានៅតែមានកង្វល់អំពីសិទ្ធិរបស់ខ្លួនក្នុងការទទួល ព័ត៌មានសាធារណៈនៅឡើយ ដោយសារតែ អជ្ញាធរទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហាក់នៅមានភាពស្ទាក់ស្ទើរក្នុងការបើកចំហឬផ្សព្វផ្សាយព័ត៌មានមួយចំនួន ព្រមទាំងកង្វះធនធាន និងសមត្ថភាពមានកម្រិត បើទោះបីជាគោលការណ៍អន្តរជាតិ និងជាតិអំពាវនាវឱ្យរដ្ឋបាល សាធារណៈយកចិត្តទុកដាក់ក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការបើកចំហព័ត៌មានក៏ដោយ។

នៅក្នុងប្រទេសជឿនលឿន និងជាពិសេសប្រទេសដែលប្រាថ្នាចង់ក្លាយខ្លួនជាប្រទេសអភិវឌ្ឍន៍ ដែលមានចំណូលមធ្យមព័ត៌មានសាធារណៈគឺជាគន្លឹះមួយនៃភាពជោគជ័យ។ សាធារណជនត្រូវការព័ត៌មាន ដើម្បីតាមដានការងាររបស់តំណាងរបស់ខ្លួននៅគ្រប់កម្រិត ហើយវិស័យឯកជនត្រូវការព័ត៌មានដើម្បីបង្កើតយុទ្ធសាស្ត្រអាជីវកម្ម សេចក្តីព្រាងផែនការរយៈពេលវែង និងធ្វើការសម្រេចចិត្តទាក់ទងនឹងការវិនិយោគផងដែរ។ ប្រសិនបើ មិនមានតម្លាភាព និងការទទួលបានឯកសារថវិកាកិច្ចសន្យាសាធារណៈ និងទិន្នន័យហិរញ្ញវត្ថុដែលរឹងមាំទេ នោះមិនមានក្រុមហ៊ុនពិតប្រាកដណាមួយទោះ ខ្នាតតូច មធ្យម ឬធំ បរទេស ឬក្នុងស្រុក នឹងវិនិយោគធនធានរបស់ខ្លួនដែលត្រូវការសម្រាប់ការរីកចម្រើននៃប្រទេសរបស់យើងឡើយ។

នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានបើកចំហទិន្នន័យទាក់ទងគម្រោងអភិវឌ្ឍថ្នាក់ជាតិមួយចំនួនដែលនេះជាការចូលរួមចំណែកដ៏សំខាន់ក្នុងការលើកកម្ពស់សិទ្ធិទទួលព័ត៌មាននៅកម្ពុជា។ ទោះជាយ៉ាងណា ក៏ ដំណើរការនៃការផ្តល់និងទទួលព័ត៌មានសាធារណៈផ្សេងៗទៀតនៅមានកម្រិតនៅឡើយ ដែលប៉ះពាល់ជាយថាហេតុដល់សិទ្ធិនិងផលប្រយោជន៍នានារបស់ប្រជាពលរដ្ឋ ជាពិសេសលើបញ្ហាសំខាន់ៗដូចជាគម្រោងអភិវឌ្ឍន៍ធំៗ នីតិវិធីលទ្ធកម្មសាធារណៈជាតិ ក៏ដូចជាសម្បទានដីសេដ្ឋកិច្ច របាយការណ៍វាយតម្លៃ

ផលប៉ះពាល់បរិស្ថាន បញ្ហាដីធ្លី និងជម្លោះផ្សេងទៀតដែលពាក់ព័ន្ធដោយផ្ទាល់លើសិទ្ធិ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋជាច្រើន។

ក្រុមការងារសិទ្ធិទទួលព័ត៌មាននៃអង្គការសង្គមស៊ីវិល និងយុវជនទទួលស្គាល់ការខិតខំប្រឹងប្រែងមួយចំនួនរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សិទ្ធិទទួលព័ត៌មាន ជាពិសេសនៅថ្នាក់ក្រោមជាតិតាមរយៈកម្មវិធីមួយចំនួនដូចជា អភិបាលកិច្ចល្អមូលដ្ឋាន ក្របខណ្ឌគណនេយ្យភាពសង្គម ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការិយាល័យច្រកចេញចូលតែមួយជាដើម។ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការចាប់ផ្តើមដំណើរការធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានទទួលបានការកោតសរសើរពីក្រុមការងារអង្គការសង្គមស៊ីវិល។ ក្នុងជំនួបជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី៥ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្តេជ្ញាចិត្តអនុម័តច្បាប់ស្តីពីការទទួលព័ត៌មានក្នុងឆ្នាំ២០២៤ ឬយ៉ាងយូរឆ្នាំ២០២៥ ក្នុងអាណត្តិសភា លើកទី៧។

ក្រុមការងារសិទ្ធិទទួលព័ត៌មាននៃអង្គការសង្គមស៊ីវិល បានចាប់ផ្តើមយុទ្ធនាការតាម Facebook ដើម្បីប្រមូលទស្សនៈពីសាធារណជនលើការគាំទ្រ ឬមិនគាំទ្រឲ្យមានច្បាប់សិទ្ធិទទួលព័ត៌មាន ដើម្បីលើកកម្ពស់ការទទួលបានព័ត៌មានសាធារណៈពិតជាក់លាក់ដល់ប្រជាពលរដ្ឋ ចាប់ពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៥។ ជាលទ្ធផលត្រឹម ថ្ងៃទី ០៧ ខែតុលា ២០២៥ មានប្រជាពលរដ្ឋដែលប្រើប្រាស់ Facebook **បានចូលរួមចំនួន១៤៩ គណនី និង១៤៥ គណនី(នាក់) បានគាំទ្រឲ្យមានច្បាប់សិទ្ធិទទួលព័ត៌មាន** ដើម្បីលើកកម្ពស់ការទទួលបានព័ត៌មានសាធារណៈពិតជាក់លាក់ ដល់ប្រជាពលរដ្ឋ។ ក្រុមការងារសិទ្ធិទទួលព័ត៌មាននៃអង្គការសង្គមស៊ីវិល នឹងបន្តយុទ្ធនាការតាម Facebook និងដោយផ្ទាល់ក្នុងឆ្នាំ ២០២៦ ដើម្បីប្រមូលទស្សនៈពីសាធារណជនលើការគាំទ្រ ឬមិនគាំទ្រឲ្យមានច្បាប់សិទ្ធិទទួលព័ត៌មាន ដើម្បីលើកកម្ពស់ការទទួលបានព័ត៌មានសាធារណៈពិតជាក់លាក់។

ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិសិទ្ធិទទួលព័ត៌មានជាសកលឆ្នាំ២០២៥ ក្រោមប្រធានបទអំពី "ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានធានាឱ្យមានសិទ្ធិទទួលព័ត៌មានបរិស្ថាននិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងយុគសម័យឌីជីថល" ក្រុមការងារសិទ្ធិទទួលព័ត៌មាននៃអង្គការសង្គមស៊ីវិល សូមស្នើជូន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាល** នូវចំណុចដូចខាងក្រោម៖

- ពន្លឿនការអនុម័តច្បាប់ស្តីពីសិទ្ធិទទួល ព័ត៌មាន ដែលស្របតាមបទដ្ឋានអន្តរជាតិក្នុងឆ្នាំ ២០២៥ យ៉ាងយូរត្រឹមឆ្នាំ២០២៦។
- សូមបញ្ជាក់ឱ្យបានច្បាស់អំពីព័ត៌មានណាខ្លះជាប្រភេទព័ត៌មានសម្ងាត់ ក្នុងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។
- ណែនាំក្រសួង មន្ទីរ និងអង្គភាពនានារបស់រដ្ឋ បើកចំហព័ត៌មានសាធារណៈឱ្យបានទូលំទូលាយ ជាពិសេស តម្លៃសេវាកម្ម នីតិវិធីក្នុងការទទួលបានសេវាសាធារណៈ និងពេលវេលាកំណត់

ដោយច្បាប់នៅកម្រិតថ្នាក់ជាតិ ព័ត៌មានសេដ្ឋកិច្ច និងការវិនិយោគ កិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន គម្រោងអភិវឌ្ឍធំៗ គម្រោងលទ្ធកម្មសាធារណៈថ្នាក់ជាតិ បញ្ហាដីធ្លី ការបណ្តេញចេញដោយបង្ខំ និងវិវាទដ៏ទៃទៀត។

- ពង្រឹង និងបង្កើតនូវយន្តការទាំងឡាយជាពិសេសយកចិត្តទុកដាក់លើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទរួមទាំងប្រព័ន្ធឌីជីថល ដើម្បីធានាថាប្រជាពលរដ្ឋ ក្រុមយុវជន ជនមានពិការភាព និងជនជាតិ ដើមភាគតិច ទទួលបាននូវព័ត៌មានពេញលេញ។
- ផ្តល់កិច្ចការពារចំពោះប្រជាពលរដ្ឋគ្រប់រូបដែលបានបង្ហាញនិងចែកចាយនូវព័ត៌មានពិតប្រាកដ ឬ ព័ត៌មានទាំងឡាយណាដែលបម្រើដល់ប្រយោជន៍សាធារណៈ។
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីសិទ្ធិទទួលព័ត៌មាន និងលើកទឹកចិត្តប្រជាពលរដ្ឋ ជាពិសេសយុវជនឱ្យចូលរួមក្នុងការស្វែងរកព័ត៌មានសាធារណៈទាំងឡាយដែលពាក់ព័ន្ធនឹង ជីវភាពរស់នៅប្រចាំថ្ងៃ។
- បង្កើតឱ្យមានបរិយាកាសកាន់តែប្រសើរឡើង សម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ ជាពិសេសយុវជនក្នុងដំណើរការអភិវឌ្ឍ ប្រទេសកម្ពុជា។

**ថ្ងៃពុធ ១រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩**
**រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២៥**

ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក **ឡាំ សុជាតិ** នាយកប្រតិបត្តិ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)
តំណាងក្រុមការងារសិទ្ធិទទួលព័ត៌មាន នៃអង្គការសង្គមស៊ីវិល(A2IWG) ចំនួន ១៨
ទូរសព្ទ៖ ០១២ ៧១៨ ៦១១